# កំណត់ហេតុ

## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៦

# អនុលោមភាពស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

*ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០២០*

*ម៉ោង ៩ :៣០ ដល់ ១២:០០ ព្រឹក*

*តាមរយៈប្រព័ន្ធអនឡាញ* ***Google Meet***






www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

# មាតិកា


១. សេចក្តីផ្តើម ............................................................ 3

២. ដំណើរការ និងលទ្ធផល ............................................................ 3

២.១ មតិស្វាគមន៍ និងបើកកម្មវិធី ............................................................ 4

២.២ បទបង្ហាញពីបច្ចុប្បន្នភាពនៃច្បាប់ស្តីពី “គណនេយ្យ និងសវនកម្ម” ............................................................ 4

៣. វេទិកាពិភាក្សា សំណួរ និងចម្លើយ ............................................................ 5

៤. បិទកម្មវិធី ដោយលោកស្រី លាង សិលា ............................................................ 10

៥. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ ............................................................ 10

៥ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ.១ ............................................................ 11

៦ឧបសម្ព័ន. ............................................................ 12





www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## ១. សេចក្តីផ្តើម

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាល និងដើម្បីចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការ គសក នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៦ តាមប្រព័ន្ធអនឡាញ (Google Meet) ក្រោមប្រធានបទ " **អនុលោមភាពស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**" ។

ត្រឹមខែធ្នូ ឆ្នាំ២០១៩ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) មានសមាជិកសរុបទាំងអស់ចំនួន ២០៨ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុត សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## ២. ដំណើរការ និងលទ្ធផល

- កិច្ចស្វាគមន៍ និងគោលបំណងវេទិការៀនសូត្រ មតិស្វាគមន៍ពី **លោក ស៊ិន សុខដុម** ប្រធានផ្នែកប្រតិបត្តិការនៃអង្គការ គ.ស.ក។
- បទបង្ហាញខ្លីអំពីសារវតានៃអនុលោមភាព និងទំនាក់ទំនង រវាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងអនុលោមភាពនៃច្បាប់រួមមាន៖ ស្តង់ដាររបាយណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ Tier 1 and Tier 2) និងលទ្ធភាពដែលនឹងដាក់ឲ្យអនុវត្តសារជាថ្មីនៅពេលអនាគត
- បទបង្ហាញខ្លីពីអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- សំនួរនិង ចម្លើយ

**លទ្ធផល៖** សិក្ខាកាមមកពីអង្គការក្នុងស្រុក និងអង្គការបរទេសដែលជាសមាជិក និងមិនមែនជាសមាជិកនៃអង្គការ គ.ស.ក ចំនួន១៧៨នាក់ បានចូលរួមតាមអនឡាញក្នុងវេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៦។ វេទិការៀនសូត្រដ៏មានសារៈសំខាន់នេះផ្តោតលើ ការអនុវត្តន៍នូវកត្តាព្វកិច្ច ភារៈកិច្ចរបស់អង្គការសមាគមន៍មិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុកឲ្យបាន ស្វែងយល់បន្ថែមពីពីសារវតានៃច្បាប់ស្តីគណនេយ្យ និងសវនកម្ម អនុក្រឹត្យពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ បន្ថែមពីនេះទៀត វេទិការៀនសូត្រនេះផ្តល់ឱកាសឲ្យអ្នកចូលរួមមានឱកាសសួរឆ្លើយដោយផ្ទាល់ទៅកាន់មន្ត្រីជំនាញមកពីក្រុមប្រឹក្សាជាតិគណនេយ្យផងដែរ។ កត្តាសំខាន់ជាងនេះ វេទិកានេះមិនត្រឹមតែជាវេទិការៀនសូត្រប៉ុណ្ណោះទេ ក៏ជាវេទិការពិគ្រោះយោបល់ដែលមន្ត្រីជំនាញអាចស្រង់យកមតិ បញ្ហាប្រឈមនានាពីអ្នកអនុវត្តន៍ផ្ទាល់យកទៅធ្វើការពិចារណា កែតម្រូវដើម្បីឲ្យ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ស្តង់ដាររបាយការណ៍នៃការរៀបចំបញ្ជីគណនេយ្យហិរញ្ញវត្ថុអាចទទួលយកបាន និងងាយស្រួលអនុវត្តន៍ទាំងអស់គ្នាទាំងវិស័យឯកជន និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញផងដែរ។

## ២.១ មតិស្វាគមន៍ និងបើកម្មវិធី

**លោក ស៊ិន សុជុម ប្រធានផ្នែកប្រតិបត្តិការ នៃអង្គការ គក.ស.៖** គោរពនឹងជំរាបសួរលោកវាគ្មិនដែលអញ្ជើញមកពីក្រុមប្រឹក្សាជាគណនេយ្យជាតិ ថ្ងៃនេះខ្ញុំមានកិត្តិយសដែលមានមតិបើកក្នុងវេទិការៀនសូត្រថ្ងៃនេះ ហិរញ្ញវត្ថុជាស្នូលដ៏សំខាន់មួយក្នុងស្ថាប័នសង្គមស៊ីវិល រដ្ឋ ឬឯកជន (ក្រុមហ៊ុន អង្គភាពមិនស្វែងរកប្រាក់ចំណេញ...)ដើម្បីឲ្យគ្រប់គ្រងល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនេះ លុះត្រាតែយើងមានការគ្រប់គ្រងដោយមានស្តង់ដារ។

ដើម្បីគ្រប់គ្រងឲ្យមានលក្ខណៈជាប្រព័ន្ធរដ្ឋាភិបាលបានរៀបចំនៃការគ្រប់គ្រងជាប្រព័ន្ធ។

គោលបំណងនៃវេទិការៀនសូត្រនេះគឺ អ្នកចូលរួម នឹងបង្កើនការយល់ដឹងពី

- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងពិន័យអន្តរការណ៍
- ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (មូលដ្ឋានសាច់ប្រាក់ និងមូលដ្ឋានគណនីបង្គរ) និងបច្ចុប្បន្នភាពនានាជុំវិញអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## ២.២ បទបង្ហាញពីបច្ចុប្បន្នភាពនៃច្បាប់ស្តីពី "គណនេយ្យ និងសវនកម្ម"

**<u>សារតានៃបទបញ្ញត្តិ៖</u>**

ច្បាប់អង្គការសមាគមមិនមែនរដ្ឋាភិបាលតម្រូវឲ្យអង្គការដាក់របាយការណ៍២

- របាយការណ៍ហិរញ្ញវត្ថុ (ដែលមិនទាន់មានចែងលំអិតថាមានរូបរាង ឬទំរង់បែបណានៅឡើយទេ)
- របាយការណ៍សកម្មភាព

ក្រោយមកច្បាប់គណនេយ្យនិងសវនកម្មបានកកើតឡើងហើយចូលជាធរមានក្នុងឆ្នាំ២០១៦ នៅក្រោយច្បាប់អង្គការសមាគមមិនមែនរដ្ឋាភិបាល។ ច្បាប់នេះមានចែងពីតួនាទីនៃក្រុមប្រឹក្សាជាតិគណនេយ្យក្នុងការកំណត់នៅស្តង់ដារ។ ច្បាប់គណនេយ្យ និងសវនកម្មមានរូបភាពស្តង់ដារស្តីពីវិស័យឯកជន និងស្ថាប័នមិនរកប្រាក់ចំណេញ(អង្គការ/សមាគម)។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ផ្អែកលើខ្លឹមសារនៃច្បាប់ក្រុមប្រឹក្សាគណនេយ្យ បានរៀបចំស្តង់ដាររបាយការណ៍រួមមួយ ខែមិនា ឆ្នាំ២០១៨ ដែលបានដាក់ឲ្យអនុវត្តសម្រាប់អង្គការសមាគម មិនទាន់បានអនុវត្តផង ក៏មានការស្នើសុំរបស់ សម្តេចក្រឡាហោម ស ខេង បានស្នើឲ្យមានការពន្យាពេលនៃការអនុវត្ត។

នៅថ្ងៃ ៣១ ខែតុលា ឆ្នាំ២០១៨ ក្រោមសេចក្តីសម្រេចរបស់សម្តេចនាយករដ្ឋមន្ត្រី ក្រុមប្រឹក្សាជាតិគណនេយ្យបានធ្វើការពន្យាពេលនៃការអនុវត្ត ដែលការពន្យាពេលនេះ មិនបានកំណត់ពេលណាមួយនឹងត្រូវអនុវត្តនៅឡើយទេ។

តំណភ្ជាប់ទៅកាន់ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម៖

https://drive.google.com/drive/folders/13g4DS1hgoLZXn0C7GFkI5xv3PlkqROFn

**អនុក្រឹត្យពិន័យអន្តរការណ៍(១ មិថុនា ២០២០)៖** អនុក្រឹត្យនេះមានការបញ្ចូលពីការពិន័យអន្តរការណ៍ចំពោះស្ថាប័នរដ្ឋ វិស័យឯកជន និងស្ថាប័នមិនរកប្រាក់ចំណេញ។

ហេតុអ្វីមានការពន្យាហើយ តែបែរជាមានអនុក្រឹត្យចែងពីការរងពិន័យទៅវិញ? (ក្នុងអនុក្រឹត្យនេះមិនមែនតែអង្គការសង្គមស៊ីវិលទេ គឺចែងសម្រាប់វិស័យឯកជនផងដែរ ដែលស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។ ប៉ុន្តែសំខាន់សម្រាប់អង្គការសមាគម គឺស្ថិតនៅក្នុងការពន្យាពេលនៅឡើយ (នេះបើតាមការសម្រេចរបស់រាជរដ្ឋាភិបាល)។ មានន័យថានៅពេលដែលរដ្ឋាភិបាលធ្វើសេចក្តីសម្រេចជាថ្មីថាត្រូវអនុវត្តកាតព្វកិច្ចនានារបស់អង្គការសមាគមមិនមែនរដ្ឋាភិបាលដែលអនុលោមទៅនឹងច្បាប់គណនេយ្យ និងសវនកម្ម អនុក្រឹត្យពិន័យអន្តរការណ៍នេះក៏អនុវត្តដូចគ្នា។

ប្រសិនបើរាជរដ្ឋាភិបាលមិនទាន់ចេញសេចក្តីសម្រេចជាថ្មី អនុក្រឹត្យនេះ មិនទាន់មានសុពលភាពចំពោះអង្គការ/ស្ថាប័នទាំងឡាយណាដែលមិនទាន់អនុវត្តទៅតាមច្បាប់នេះនៅឡើយ។ ហើយនៅពេលដែលច្បាប់នេះអនុវត្តក្រុមប្រឹក្សាជាតិគណនេយ្យជាអ្នកអនុវត្ត។

តំណភ្ជាប់ទៅកាន់អនុក្រឹត្យពិន័យអន្តរការណ៍៖

https://drive.google.com/drive/folders/13g4DS1hgoLZXn0C7GFkI5xv3PlkqROFn

## ៣. វេទិកាពិភាក្សា សំណួរ និងចម្លើយ

**សំណួរទី១៖** ការពន្យាពេលនៃការប្រើប្រាស់ស្តង់ដារគណនេយ្យ ពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីដើម្បីស្នើសុំ

លេខកូដគណនេយ្យអត្តសញ្ញាណកម្ម។ តើវាអាចពាក់ពន្ធ័ទៅនឹងការចុះបញ្ជីទេ?

**ចម្លើយទី១៖** ការសុំលេខអត្តសញ្ញាណកម្មនេះ គឺការណែនាំដែលចេញមុននៃការសម្រេចជាគោលការណ៍របស់រាជរដ្ឋាភិបាលការពន្យាពេលនៃការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្មសម្រាប់អង្គការ/សមាគម។ ទាក់ទិននឹងការស្នើសុំលេខអត្តសញ្ញាណកម្មនេះ បើមិនទាន់ចាំបាច់ក៏បានដែរ ព្រោះការអនុវត្តកាតព្វកិច្ចនេះវាជាផ្នែកមួយនៃការកំណត់នៅក្នុងច្បាប់បទដ្ឋានគតិយុត្តនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ ប៉ុន្តែប្រសិនបើស្ថាប័នគិតថាចង់ធ្វើយឲ្យហើយ ទំរាំច្បាប់ស្តីពីគណនេយ្យ និងសវនកម្មចាប់ផ្តើមអនុវត្តក៏បាន (ក្រុមប្រឹក្សាជាតិគណនេយ្យ នៅតែទទួលយកបាន)។

**សំណួរទី២៖** តើអាចពាក់ព័ន្ធនឹងការពិន័យដែរទេ? ព្រោះExternal Audit គេទាមទារឲ្យមានការចុះបញ្ជីយកលេខអត្តសញ្ញាណកម្មជាមួយ NAC?

**ចម្លើយទី២៖** ការមិនមានលេខអត្តសញ្ញាណកូដគណនេយ្យជាមួយ NAC គឺមិនស្ថិតក្នុងបញ្ជីពិន័យអន្តរការណ៍ទេ។

**សំណួរទី៣៖** ក្នុងប្រកាសពិន័យអន្តរការណ៍ការប្រើប្រាស់ភាសាជាភាសាខ្មែរ និងរូបិយបណ្ណ័ជាលុយរៀល។ ត្រង់ចំណុចនេះ ហាក់បីដូចជាបញ្ហាសបន្តិចព្រោះ អង្គការសង្គមស៊ីវិល ប្រើប្រាស់របាយការណ៍ទៅម្ចាស់ជំនួយជាភាសាអង់គ្លេស (រូបិយបណ្ណ័ដុល្លា)។ពេលដែលដាក់របាយការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (NAC) តើអាចប្រើជាភាសាអង់គ្លេសបានទេ? តើមានលក្ខខណ្ឌតម្រូវឲ្យ Auditorធ្វើរបាយការណ៍ជាពីរជាភាសា (ខ្មែរ/អង់គ្លេស)បានទេ?

**ចម្លើយទី៣៖** ច្បាប់ឬលិខិតបទដ្ឋានគឺត្រូវគោរពតាមរដ្ឋធមនុញ្ញដែលប្រើប្រាស់ភាសាជាតិ(ខ្មែរ)ជាគោល។ ក្នុងច្បាប់គឺបានចែងថារាល់របាយការណ៍ត្រូវតែគោរពជាដាច់ខាតធ្វើជាភាសាខ្មែរ។ ទាក់ទងនឹងរបាការណ៍សវនកម្មដែលចេញដោយសវនករឯករាជនេះ ត្រូវប្រើជាភាសាខ្មែរ រីឯភាសាអង់គ្លេសជារឿងបន្ទាប់បន្សំប៉ុណ្ណោះ។

**សំណូមពរ៖** សូមឲ្យក្រុមប្រឹក្សាជាតិគណនេយ្យ អញ្ជើញស្ថាប័នAuditor មកបញ្ជាក់ការងារជាមួយគ្នាពីកាតព្វកិច្ចច្បាប់។ ដើម្បីឲ្យAuditor យកចិត្តទុកដាក់ពីកាតព្វកិច្ចរបស់ខ្លួន ទៅកាន់អតិថិជន។ សូមឲ្យ មានការផលិតរបាយការណ៍ជាពីរភាសា(ខ្មែរ/អង់គ្លេស) ព្រោះសង្គមស៊ីវិល ប្រើភាសាអង់គ្លេសជាគោលដោយដាក់ជូនទៅម្ចាស់ជំនួយ និងភាសាខ្មែរជារបាយការណ៍ទៅNAC។ ព្រោះពេលកន្លងមកការស្នើឲ្យមានការ

ប្រែសម្រួលជាភាសាខ្មែរ គឺត្រូវបានចាយថវិកាគុណនឹងពីរ (x2)។)

**ការឆ្លើយតបសំណើ៖** ក្រុមប្រឹក្សាជាតិគណនេយ្យទទួលយកសំណូមពរនេះ ហើយយកការណ៍នេះទៅឆ្លងថ្នាក់ដឹកនាំបន្ថែមទៀត។

**បញ្ជាក់បន្ថែម៖** របាយការណ៍សវនកម្មគឺតម្រូវឲ្យធ្វើជាភាសាខ្មែរ។

**សំណួរទី៤៖** តើវិញ្ញាបនបត្រលេខអត្តសញ្ញាណកម្ម (ID) របស់អង្គការ/សមាគមដែលបានដាក់ពាក្យស្នើសុំកន្លងមក តើពេលណាចែកជូន?

**ចម្លើយទី៤៖** លក្ខខណនេះមានពីរ (ទី១). ដោយសារលក្ខខណដែលឲ្យមានការស្នើសុំ ID កន្លងទៅបានចេញមុនសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការពន្យាពេលអនុវត្តច្បាប់ស្តីពីសវនកម្ម។ កន្លងមកក្រុមការងារនៃក្រុមប្រឹក្សាជាតិគណនេយ្យបានចេញ ID ទៅអង្គការដែលបានដាក់ពាក្យស្នើសុំច្រើនមកហើយ តែក៏មានឧបសគ្គមួយចំនួនដែល ព្រោះមានអង្គការខ្លះខ្វះឯកសារ ហើយក្រុមការងារមិនអាចផ្តល់ជូន ID ដោយមិនមានឯកសារគ្រប់គ្រាន់នោះឡើយ។ (ទី២). ក្រុមការងារនឹងពិនិត្យមើលឡើងវិញនូវអង្គការណាដែលបានដាក់ពាក្យហើយ តែមិនទាន់បានID ហើយធ្វើការចែកជូនឲ្យបានឆាប់។

**សំណួរទី៥៖** ការស្នើសុំប្តូរភាសានិង រូបិយប័ណ្ណក្នុងរបាយការណ៍ហិរញ្ញវត្ថុ តើអាចដាក់បាននៅពេលណា?
**ចម្លើយទី៥៖** ភាសាខ្មែរ (ប្រាក់រៀល)ជាការចាំបាច់ទាំងក្នុងបញ្ជីគណនេយ្យ និងក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយភាសាអង់គ្លេសជាបន្ទាប់បន្សំ។ កន្លងមកក្រុមប្រឹក្សាជាតិគណនេយ្យ បានទទួលយោបល់ត្រឡប់ច្រើនលើប្រព័ន្ធគណនេយ្យ មិនអាចប្រើភាសាខ្មែរបាន ហើយច្បាប់តម្រូវឲ្យប្រើជាភាសាខ្មែរ ។ បន្ទាប់ពីចេញអនុក្រឹត្យពិន័យអន្តរកាលរួច ក្រុមការងារកំពុងទទួលយោបល់បន្ថែមទៀតពីអ្នកអនុវត្តន៍ ដូចជាក្រុមហ៊ុន អង្គការសមាគមន៍ ហើយក្រុមការងារនឹងប្រមូលធាតុចូលបន្ថែម ដើម្បីចេញសេចក្តីណែនាំ រឺប្រកាសណែនាំ ធ្វើឲ្យងាយស្រួលអនុវត្តន៍។ ជានិតិវិធីត្រូវធ្វើការស្នើសុំប្រើភាសាអង់គ្លេស អមជាមួយភាសាខ្មែរ ប៉ុន្តែមិនមែនសុំដើម្បីប្រើភាសាអង់គ្លេសជំនួយភាសាខ្មែរទេ។ រីឯនិតិវិធីស្នើសុំ នឹងមានសេចក្តីណែនាំបន្ថែម ព្រោះឥឡូវស្ថិតក្នុងតំណាក់កាលប្រមូលនូវធាតុចូលទាំងឡាយ ដើម្បីធ្វើសេចក្តីណែនាំ រឺប្រកាសណែនាំពេលក្រោយ។

**សំណួរបញ្ជាក់បន្ថែម៖** មាត្រា៦ ចំណុច(ខ) ក្នុងបញ្ជីរគណនេយ្យត្រូវប្រើជាភាសាខ្មែរ បើមិនប្រើត្រូវពិន័យ។

**ចម្លើយ៖** ភាសាខ្មែរ និងប្រាក់រៀល ជាលក្ខខណតម្រូវចាំបាច់ក្នុងច្បាប់ ឯភាសាអង់គ្លេសជាលក្ខខណបន្ទាប់បន្សំ ហើយអនុញ្ញាតិបានតែភាសាអង់គ្លេសតែមួយទេ ភាសាដទៃទៀតមិនអនុញ្ញាត្តិឡើយ។ ហើយ


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ភាសាខ្មែរ និងប្រាក់រៀលតម្រូវឲ្យប្រើ ទាំងក្នុងបញ្ជីគណនេយ្យផ្ទៃក្នុងរបស់ស្ថាប័នផង និងរបាយការណ៍ហិរញ្ញវត្ថុផង។ ទិដ្ឋភាពច្បាប់និយាយបែបនេះព្រោះមិនអាចចាកឆ្ងាយពីរដ្ឋធម្មនុញ្ញបានទេ រីឯទិដ្ឋភាពអនុវត្តន៍ក្រុមការងារនៃក្រុមប្រឹក្សាជាតិគណនេយ្យកំពុងសិក្សាប្រមូលជាតុចូល ឧទាហរណ៍៖ ក្រុមហ៊ុនទិញ Software ពីក្រៅប្រទេសដូចជា QuickBooks អាចមិនមានជាភាសាខ្មែរ។ តែប្រសិនបើប្រើManual (Excel) គឺអាចប្រើភាសាខ្មែរបាន តែមានភាគតិចណាស់ដែលសមាគមអង្គការមិនមែនរដ្ឋាភិបាលប្រើប្រព័ន្ធនេះ។ ដោយហេតុនេះ បញ្ជីគណនេយ្យមិនទាន់សម្រេចដាច់ស្រេចនៅឡើយ។ )

**សំណួរទី៦៖** តើទំហំថវិកាប៉ុន្មានដែលត្រូវដាក់ឲ្យរងសវនកម្ម?

**ចម្លើយទី៦៖** លក្ខណទី១៖ ចំណាយប្រចាំឆ្នាំ ៥០ម៉ឺនដុល្លាឡើងទៅ។ លក្ខណទី២៖ ចំនួនកម្មករនិយោជិក (២០ នាក់ឡើងទៅ) ប្រសិនបើក្រោមចំនួននេះ មិនរងសវនកម្មទេ។)

**សំណួរទី៧៖** ជំពូក៦ មាត្រា១៨ (អវសានប្បញ្ញត្តិ) នៃអនុក្រឹត្យពិន័យអន្តរការណ៍ចែងថា″ បទបញ្ញត្តិទាំងឡាយដែលផ្ទុយទៅនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍″ តើចំណុចនេះអាចនិរាករណ៍ទៅនឹង សេចក្តីជូនដំណឹង(សេចក្តីជូនដំណឹងស្តីពីការពន្យាពេលនៃការអនុវត្តន៍ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម)រឺទេរឺយ៉ាងណា?

**ចម្លើយទី៧៖** អនុក្រឹត្យគឺនិយាយពីការពិន័យអន្តរការណ៍ (ពិន័យជាលុយ) និងប្រភេទបទល្មើស គឺមិនទាក់ទិននឹងសេចក្តីជូនដំណឹង សេចក្តីប្រកាសរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ។ ក្នុងន័យនេះ ចង់សំដៅទៅ ប្រសិនបើមានបទបញ្ញត្តិដែលមានពីមុនមកដែលចែងពីការមិនអនុវត្តន៍ច្បាប់គណេយ្យ រឺកាតព្វកិច្ចនានាដែលមានចែង (ឧទាហរណ៍៖ មិនកាន់បញ្ជីរគណនេយ្យ -ត្រូវពិន័យ២០,០០០រៀល។ ដូចនេះការចែងពីមុននឹងត្រូវអវសាន្ត ហើយអនុវត្តតាមអនុក្រឹត្យថ្មីពីប្រភេទបទល្មើស និងទំហំទឹកប្រាក់)។ បញ្ជាក់ត្រង់ចំណុចនេះ មួយនិយាយពីទិដ្ឋភាពក្នុងការអនុវត្តមួយនិយាយពីទំហំទឹកប្រាក់ និងប្រភេទបទល្មើស។

**សំណួរទី៨៖** បន្ទាប់ពីធ្វើ Accrual items ក្នុងការកត់ត្រាក្នុងប្រព័ន្ធ ១០០%។ តើការដាក់ស្នើសុំនោះដល់ណាហើយ?

**ចម្លើយទី៨៖** បន្ទាប់ពីបានទទួលសំណើ ក្រុមការងារមិនទានសម្រេចជាផ្លូវការនៅឡើយទេ តែក្រុមការងារកំពុងយកមកដាក់បញ្ចូលក្នុងសេចក្តីព្រាងទំរង់របាយការណ៍ស្តង់ដារគណនេយ្យ Tier 2 ប៉ុន្តែក្នុងដំណាក់


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

កាលសុំយោបល់បន្ថែមពីខាងក្រុមហ៊ុនគណនេយ្យបន្ត។ ឯការធ្វើសេចក្តីឆ្លើយតប នឹងធ្វើឡើងនៅពេលដែលមានវេទិកាប្រជុំពិគ្រោះយោបល់ជាមួយ គ.ស.ក លើសេចក្តីព្រាងលើទំរង់របាយការណ៍ស្តង់ដារគណនេយ្យ។ បញ្ជាក់ន្ថែម៖ បច្ចុប្បន្នអង្គការសមាគមមានសេរីភាពក្នុងការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុតាមមូលដ្ឋានណាក៏បាន ហើយការរាយការណ៍របាយការណ៍ដែលខ្លួនធ្លាប់ប្រើកន្លងមកចុះ លុះត្រាតែស្តង់ដារថ្មី និងការណែនាំថ្មីពីរាជរដ្ឋាភិបាលតម្រូវឲ្យអង្គការសមាគម ចាប់ផ្តើមអនុវត្តន៍តាមច្បាប់គណនេយ្យ និងសវនកម្មទើបអនុវត្ត។

**សំណួរទី៩៖** តើមានដំណោះស្រាយក្នុងការឲ្យមានការប្រើបញ្ជីគណនេយ្យជាភាសាអង់គ្លេសបានទេ ព្រោះអង្គការបរទេសមានការត្រួតពិនិត្យពីក្រៅប្រទេស?

**ចម្លើយទី៩៖** មិនអាចបានទេ ត្រូវអនុវត្តន៍តាមច្បាប់។

**សំណួរទី១០៖** តើអង្គការសង្គមស៊ីវិល ទាក់ទងទៅNAC ដោយរបៀបណាដើម្បីដាក់លិខិតស្នើសុំ ID?

**ចម្លើយទី១០៖** អញ្ជើញទៅការិយាល័យ NAC (ក្បែរវត្តភ្នំ) ដោយផ្ទាល់ ដែលមន្ត្រីទទួលបន្ទុកខាងផ្នែកសង្គមស៊ីវិលគឺលោក ហាក់ សីហា Tel: 070/061 929237។

**សំណូមពរ៖** ស្នើសុំឲ្យទុកពេលយូរបន្តិចដើម្បីរៀបចំខ្លួន នៅពេលដែលសេចក្តីប្រកាសឲ្យអនុវត្ត នាពេលខាងមុខ។ ស្នើសុំអនុសាសន៍ពី លោក សេង តុលា តើអង្គការសមាគមគួរចាប់ផ្តើមអនុវត្តន៍ពេលណា?

**ចម្លើយ៖** អង្គការសង្គមស៊ីវិលគួរតែចាប់ផ្តើមពីពេលឥឡូវ ដើម្បីឆ្ពោះទៅការអនុវត្តពេញលេញ។ ក្នុងប្រកាសរបស់ក្រសួងនាពេលកន្លងមក គឺអនុញ្ញាត្តិឲ្យអង្គការសមាគម ប្រើស្តង់ដារជាធរមាន គឺមាន២ គឺ CIFRF CIFRS FOR SME។ទាំងពីរនេះអាចប្រើស្តង់ដារមួយណាក៏បានដែរ។ ប្រសិនបើប្រើស្តង់ដារទាំងពីរនេះគ្រាន់តែជូនដំណឹង ដោយមិនមានការឆ្លើយតបត្រឡប់ក៏បាន។ ប្រសិនបើប្រើរបាយការណ៍ Cash Basis (មិនា ២០១៨) ក៏អាចប្រើបានដែរ។ ទំរង់ស្តង់ដារទាំងពីរនេះអាចរកបាននៅ វេបសាយរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ http://www.naccambodia.gov.kh/។

កាតព្វកិច្ចសំខាន់របស់អង្គការសមាគមមិនមែនរដ្ឋាភិបាលលើអនុក្រឹត្យពិន័យអន្តរការណ៍គួរពិនិត្យទៅលើ៖

- មាត្រា២ "...គ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីជាមួយស្ថាប័នជំនាញ..."មានន័យថាអង្គការសមាគមដែលមិនចុះបញ្ជីរទេ គឺមិនស្ថិតនៅក្នុងដែនសម្តកិច្ចនៃអនុក្រឹត្យនេះឡើយ។
- ផ្នែកទី២ មាត្រា៦៖ ការពិន័យ...

- ការប្រើការីបរិច្ឆេទគណនេយ្យឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់
- ការស្នើសុំការីបរិច្ឆេទខុសពីថ្ងៃ៣១ ខែធ្នូ គឺត្រូវសុំការអនុវញ្ញាត្តិពី NAC
- ការប្រើភាសា និងរូបិយប័ណប្រាក់រៀលក្នុងបញ្ជីហិរញ្ញវត្ថុ
- ការមិនដាក់ រីឃើតយ៉ាវក្នុងការដាក់របាយការណ៍មកក្រុមប្រឹក្សាជាតិគណនេយ្យ (ទោះបីរងសវនកម្មរឺមិនរងសវនកម្មក៏ជាកាតព្វកិច្ចដែលត្រូវដាក់បញ្ជូនរបាយការណ៍)
- ការមិនកាន់បញ្ជីរ (មិនមានឯកសារគណនេយ្យ និងឯកសារគាំទ្រឲ្យបានត្រឹមត្រូវ)
- របាយការណ៍គណនេយ្យហិរញ្ញវត្ថុត្រូវគោរពតាមស្តង់ដារគណនេយ្យជាធរមាន
- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យរងសវនកម្មឯករាជ្យ
- ការមិនយករបាយការណ៍ហិរញ្ញវត្ថុដែលរៀបចំតាមស្តង់ដារទៅបំពេញកាតព្វកិច្ចសារពើពន្ធ
- ការរក្សាឯកសារគណនេយ្យតាមច្បាប់កំណត់ (យ៉ាងហោចណាស់១០ឆ្នាំយ៉ាងតិច)

***លេខសម្រាប់ចូលរួម ក្រុមTelegram ជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ (មន្រ្តីទទួលបន្ទុក ហាក់ សីហា Tel: 070/061 929237)

## ៤. បិទកម្មវិធី ដោយលោកស្រី លាង សិលា

លោកស្រី **លាង សិលា** ជា Junior Finance Manager, Johanniter International Assistant និងតំណាងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុនៃអង្គការ គក.ស.។ លោកស្រីបានជំរាបសួរទៅកាន់អង្គវេទិកាសិក្សារៀនសូត្រទាំងមូល និងបានធ្វើការណែនាំខ្លួន បន្ទាប់មកទៀតលោកស្រីបានសង្ខេបពីដំណើរការរៀនសូត្រមួយព្រឹកពេញនេះ ដែលបានចែកចាយដោយលោក **សេង តុលា**។ លោកស្រីបានជូនពរដល់លោក វាគ្មិន អ្នកចូលរួម និងក្រុមការងារអង្គការ គ.ស.ក ដែលបានរៀបចំវេទិការៀនសូត្រនេះឡើង។

## ៥. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ

បន្ទាប់ពីបញ្ចាប់វេទិកាសិក្សារៀនសូត្រស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ លោក សុខ ណេង អ្នកសម្របសម្រួលផ្នែកសិក្សារៀនសូត្របានសំណូមពរឲ្យសិក្ខាកាមផ្ដល់នូវព័ត៌មានត្រឡប់ដោយពិភាក្សាទៅលើប្រធានបទ និងការវាយតំលៃទៅលើវេទិកាសិក្សារៀនសូត្រទាំងមូលតាមរយៈប្រព័ន្ធអនឡាញ(Google Forum)។ ខាងក្រោមគឺជាលទ្ធផលលម្អិតនៃមតិយោបល់ត្រឡប់របស់សិក្ខាកាមចំនួន ២៥ នាក់ ក្នុង

ចំណោមសិក្ខាកាមក្នុងវេទិកាសរុប ១៧៨ នាក់។

## ៥.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ




តាមក្រាហ្វិកខាងស្តាំបង្ហាញថា សិក្ខាកាមពេញចិត្តខ្លាំងចំពោះវេទិកានេះ ព្រោះសិក្ខាកាមបានដាក់ពិន្ទុ ៦៤% កំរិតលេខ៤ និង២៨%កំរិតលេខ៥។ តាមតារាងទី១ខាងក្រោម បង្ហាញថា សិក្ខាកាមយល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញដែលបានទទួល ៥៤% និង៣៦%នៅកំរិតលេខ៤និងលេខ៥។ សិក្ខាកាមបង្ហាញថា ប្រធានបទនេះទាក់ទងនឹងការងាររបស់គាត់ ដែលគាត់បានដាក់ពិន្ទុ ៦៨%កំរិតលេខ៥ និង២៤%នៅកំរិតលេខ៤ និងគោលបំណងវេទិកាត្រូវបានបំពេញ៤៤%កំរិតលេខ៤ និង៣២%កំរិតលេខ៥។ លើសពីនេះទៀត វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ ៥៦% ក្នុងកំរិតលេខ៤ បង្ហាញថាសិក្ខាកាមពេញចិត្តខ្លាំង។

តារាងទី១៖

| **តើអ្នកយល់យ៉ាងដូម្តេចចំពោះចំណុចខាងក្រោម?សូមដាក់ពិន្ទុពី ១ ដល់ 5**<br>១ = មិនពេញចិត្តសោះ ៥ = ពេញចិត្តខ្លាំងណាស់ | ១<br>% | ២<br>% | ៣<br>% | ៤<br>% | ៥<br>% | សរុប<br>% | ពិន្ទុមធ្យម |
|---|---|---|---|---|---|---|---|
| ១.ការលើកទឹកចិត្តឲ្យសួរសំណួរ និងទំនាក់ទំនងតាមប្រអប់សារ | 0 | 0 | ៨ | ៥៦ | ៣៦ | ១០០ | ៤ |
| ២.ប្រធានបទនេះទាក់ទងនឹងការងាររបស់ខ្ញុំ | 0 | 0 | ៨ | ២៤ | ៦៨ | ១០០ | ៥ |
| ៣.មាតិកាត្រូវបានរៀបចំយ៉ាងល្អ ហើយងាយយល់ | 0 | ៨ | ៤ | ៦៨ | ២០ | ១០០ | ៤ |
| ៤.ឯកសារដែលបានផ្តល់ឲ្យមានសារៈប្រយោជន៍មែនទែន | 0 | 0 | ៤ | ៥៦ | ៤០ | ១០០ | ៤ |
| ៥.វាគ្មិន/អ្នកសម្របសម្រួលមានការត្រៀមរៀបចំយ៉ាងល្អ | 0 | 0 | ១២ | ៤៨ | ៤០ | ១០០ | ៤ |
| ៦.វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ | 0 | ៨ | ១២ | ៥៦ | ២៤ | ១០០ | ៤ |
| ៧.គោលបំណងវេទិកាត្រូវបានបំពេញ | 0 | ៨ | ១៦ | ៤៤ | ៣២ | ១០០ | ៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨.ការបែងចែកពេលវេលាសម្រាប់វេទិកាមានរយៈពេលគ្រប់គ្រាន់ | ០ | ០ | ១២ | ៧៦ | ១២ | ១០០ | ៤ |
| ៩.យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញ | ០ | ០ | ២០ | ៤៤ | ៣៦ | ១០០ | ៤ |
| ពិន្ទុមធ្យមសរុប | | | | | | | ៣៨ |

## ៦.ឧបសម្ព័ន

- **របាយការណ៍វាយតម្លៃវេទិកាសិក្សារៀនសូត្រ**

### ១. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ

បន្ទាប់ពីបញ្ចប់វេទិកាសិក្សារៀនសូត្រស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ លោក សុខ ណោង អ្នកសម្របសម្រួលផ្នែកសិក្សារៀនសូត្របានសំណូមពរឲ្យសិក្ខាកាមផ្ដល់នូវព័ត៌មានត្រឡប់ដោយពិភាក្សាទៅលើប្រធានបទ និងការវាយតំលៃទៅលើវេទិកាសិក្សារៀនសូត្រទាំងមូលតាមរយៈប្រព័ន្ធអនឡាញ(Google Forum)។ ខាងក្រោមគឺជាលទ្ធផលលម្អិតនៃមតិយោបល់ត្រឡប់របស់សិក្ខាកាមចំនួន ២៥ នាក់ ក្នុងចំណោមសិក្ខាកាមក្នុងវេទិកាសរុប ១៧៨ នាក់។

### ១.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ




តាមក្រាហ្វិកខាងស្ដាំបង្ហាញថា សិក្ខាកាមពេញចិត្តខ្លាំងចំពោះវេទិកានេះ ព្រោះសិក្ខាកាមបានដាក់ពិន្ទុ ៦៤% កំរិតលេខ៤ និង២៨%កំរិតលេខ៥។ តាមតារាងទី១ខាងក្រោម បង្ហាញថា សិក្ខាកាមយល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញដែលបានទទួល ៤៤% និង៣៦%នៅកំរិតលេខ៤និងលេខ៥។ សិក្ខាកាមបង្ហាញថា ប្រធានបទនេះទាក់ទងនឹងការងាររបស់គាត់ ដែលគាត់បានដាក់ពិន្ទុ ៦៨%កំរិតលេខ៥ និង២៤%នៅកំរិតលេខ៤ និងគោលបំណងវេទិកាត្រូវបានបំពេញ៤៤%កំរិតលេខ៤ និង៣២%កំរិតលេខ៥។ លើសពីនេះទៀត វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ ៥៦% ក្នុងកំរិតលេខ៤ បង្ហាញថាសិក្ខាកាមពេញចិត្តខ្លាំង។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

តារាងទី១៖

| តើអ្នកយល់យ៉ាងដូចម្តេចចំពោះចំណុចខាងក្រោម?សូមដាក់ពិន្ទុពី ១ ដល់ 5<br>១ = មិនពេញចិត្តសោះ ៥ = ពេញចិត្តខ្លាំងណាស់ | ១<br>% | ២<br>% | ៣<br>% | ៤<br>% | ៥<br>% | សរុប<br>% | ពិន្ទុមធ្យម |
|---|---|---|---|---|---|---|---|
| ១.ការលើកទឹកចិត្តឲ្យសួរសំណួរ និងទំនាក់ទំនងតាមប្រអប់សារ | 0 | 0 | ៨ | ៥៦ | ៣៦ | ១00 | ៤ |
| ២.ប្រធានបទនេះទាក់ទងនឹងការងាររបស់ខ្ញុំ | 0 | 0 | ៨ | ២៤ | ៦៨ | ១00 | ៥ |
| ៣.មាតិកាត្រូវបានរៀបចំយ៉ាងល្អ ហើយងាយយល់ | 0 | ៨ | ៤ | ៦៨ | ២0 | ១00 | ៤ |
| ៤.ឯកសារដែលបានផ្តល់ឲ្យមានសារៈប្រយោជន៍មែនទែន | 0 | 0 | ៤ | ៥៦ | ៤0 | ១00 | ៤ |
| ៥.វាគ្មិន/អ្នកសម្របសម្រួលមានការត្រៀមរៀបចំយ៉ាងល្អ | 0 | 0 | ១២ | ៤៨ | ៤0 | ១00 | ៤ |
| ៦.វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ | 0 | ៨ | ១២ | ៥៦ | ២៤ | ១00 | ៤ |
| ៧.គោលបំណងវេទិកាត្រូវបានបំពេញ | 0 | ៨ | ១៦ | ៤៤ | ៣២ | ១00 | ៤ |
| ៨.ការបែងចែកពេលវេលាសម្រាប់វេទិកាមានរយៈពេលគ្រប់គ្រាន់ | 0 | 0 | ១២ | ៧៦ | ១២ | ១00 | ៤ |
| ៩.យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញ | 0 | 0 | ២0 | ៤៤ | ៣៦ | ១00 | ៤ |
| ពិន្ទុមធ្យមសរុប | | | | | | | ៣៨ |

## ១.២.ចំណុចសិក្ខាកាមរៀនសូត្របានច្រើនជាងគេ

តាមលទ្ធផលក្នុងក្រាហ្វិកទី១បង្ហាញថា មានបួនចំណុចដែលសិក្ខាកាមរៀនសូត្របានច្រើនជាងគេ ។ លើសពីនេះទៀត ចំណុចដែលលេចធ្លោជាងគេមានពីរគឺ យល់ច្បាស់ពីអនុក្រឹត្យលេខ៧៩ស្តីពីការពិន័យអន្តរការណ៍ ៥៦% និងការប្រើប្រាស់ភាសារ និងរូបិយប័ណ្ណក្នុងស្តងដាររបាយការណ៍ និងបញ្ជីគណនេយ្យ ៣៦% ដែលបង្ហាញថាសិក្ខាកាមក្នុងវេទិកានេះរៀនសូត្របានច្រើនជាងគេ។

ក្រាហ្វិកទី១៖




## ១.៣.ចំណុចសិក្ខាកាមនៅតែត្រូវការពន្យល់បន្ថែមពីវេទិកាលើកនេះ

តាមលទ្ធផលបង្ហាញថា សិក្ខាកាមត្រូវការពន្យល់បន្ថែមលើចំណុចចំនួនបួនពីវេទិកានេះមានដូចជា ១.គំរូរបាយការណ៍ស្តង់ដារគណនេយ្យកម្ពុជា ២.ដំណើរការ និងឯកសារសម្រាប់ស្នើសុំ ID ពី NAC ៣.គំរូស្នើសុំប្រើប្រាស់ភាសារអង្គគ្លេស និងរូបិយបណ្ណប្រាស់ដុល្លារក្នុងបញ្ជីគណនេយ្យ និង៤.អនុក្រឹត្យលេខ៧៩ ស្តីពីការពិន័យអន្តរការណ៍។ ទោះបីជាយ៉ាងណា មានចំណុចមួយដែលមានកំរិតខ្ពស់ជាងគេគឺគំរូរបាយការណ៍ស្តង់ដារគណនេយ្យកម្ពុជា ៤៨% ។

ក្រាហ្វិកទី២៖





www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## ១.៤.ចំណុចមួយចំនួនដែលសិក្ខាកាមនឹងយកទៅអនុវត្តក្នុងស្ថាប័ន

តាមលទ្ធផលក្នុងតារាងទី២បង្ហាញថា សិក្ខាកាមនឹងយកចំណុចចំនួនបួនខាងក្រោមទៅអនុវត្តក្នុងស្ថាប័ន។ ចំណុចពីរដែលទទួលបានកំរិតខ្ពស់ជាងគេគឺរៀបចំស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់NAC ៣៦% និង ស្នើសុំប្រើប្រាស់ភាសារ និងរូបិយបណ្ណដុល្លារអមក្នុងបញ្ជីនិងរបាយការគណនេយ្យ ២៤%។

តារាងទី២៖

| ចំណុចមួយចំនួននឹងទៅអនុវត្តក្នុងស្ថាប័នរបស់ខ្ញុំ | ចំនួន% |
|---|---|
| រៀបចំស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់NAC | 36% |
| ស្នើសុំប្រើប្រាស់ភាសារនិងរូបិយបណ្ណដុល្លារអមក្នុងបញ្ជីនិងរបាយការគណនេយ្យ | 24% |
| ត្រួតពិនិត្យប្រព័ន្ធគណនេយ្យក្នុងស្ថាបន ហើយពិចារណាចំណុងអាចអនុលោមបាន | 12% |
| ប្រើប្រាស់ភាសារនិងរូបិយបណ្ណជាភាសារខ្មែរក្នុងរបាយការណ៍គណនេយ្យ | 8% |
| ស្នើសុំ ID ពីក្រុមប្រឹក្សាជាតិគណនេយ្យ | 8% |

## ១.៥.ចំណុចមួយចំនួននឹងធ្វើឲ្យវេទិកាមានប្រសិទ្ធភាពជាងនេះ

ក្រាហ្វិកទី៣បង្ហាញថា មានចំណុចកែលម្អចំនួនបួន តែចំណុចចំនួនពីរដែលមានភាគរយខ្ពស់ជាងគេគឺ គួរមានពេលវេលាយូជាងនេះ និងវាគ្មិនគួរតែរៀបចំបទបង្ហាញ ។ជាក់ស្តែងនៅក្នុងវេទិកានេះវាគ្មិនមិនបានរៀបចំបទបង្ហាញទេ ព្រោះគាត់ប្រាប់ថាស្តង់ដាររបាយការណ៍នៅដំដែល តែគាត់និងធ្វើបច្ចុប្បន្នភាពអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ និងឆ្លើយនូវសំណួររបស់សិក្ខាកាម។

ក្រាហ្វិកទី៣៖




## ១.៦.ប្រធានបទដែលសិក្ខាកាមត្រូវការរៀនសម្រាប់វេទិកាលើកក្រោយ

តាមលទ្ធផលវាយតម្លៃបង្ហាញថា មានប្រធានបទចំនួនបីដែលសិក្ខាកាមបានលើកឡើងសម្រាប់វេទិការៀនសូត្រលើកក្រោយ។ ក្នុងនោះមានប្រធានបទចំនួនពីរដែលទទួលកំរិតខ្ពស់ជាងគេ គឺរបៀបធ្វើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជានិងការពន្យល់ចំណុចនិមួយៗ និងការអនុវត្តការប្រកាស់ពន្ធតាមប្រព័ន្ធអនឡាញ(E-Filing)។

ក្រាហ្វិកទី៤៖






www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

• **របៀបវារៈ**

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៩:២០-០៩:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គសក |
| ០៩:៣០-០៩:៤០ | កិច្ចស្វាគមន៍ និងគោលបំណងវេទិការៀនសូត្រ<br>មតិស្វាគមន៍ពី **លោក ស៊ិន សុខជុម** ប្រធានផ្នែកប្រតិបត្តិការ នៃអង្គការ គ.ស.ក | **លោក សុខ ណេង**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ<br>អង្គការ គ.ស.ក |
| ០៩:៤០-០៩:៥០ | ការណែនាំពីរបៀបប្រើ Google Meet និងបទបញ្ជាផ្ទៃក្នុងវគ្គ | |
| ០៩:៥០-១០:២០ | បទបង្ហាញខ្លីអំពីសារៈតានៃអនុលោមភាព និងទំនាក់ទំនងរវាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងអនុលោមភាពនៃច្បាប់រួមមាន៖ ស្តង់ដាររបាយណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ Tire 1 and Tire 2) និងលទ្ធភាពដែលនឹងដាក់ឲ្យអនុវត្តសារជាថ្មីនៅពេលអនាគត | **លោក សេង តុលា**<br>ក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) |
| ១០:២០-១០:៥០ | បទបង្ហាញខ្លីពីអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម | |
| ១០:៥០-១១:៥០ | សំណួរ និង ចម្លើយ | **សម្របសម្រួលដោយ៖**<br>**លោក យឿង សុធារ៉ា** ប្រធានផ្នែកកសាងភាពជាដៃគូ បណ្តាញ និងឥស្សមតិ នៃអង្គការ គ.ស.ក |
| ១១:៥០-១២:00 | បូកសរុប និង កម្មវិធីបិទ | **លោកស្រី** Leang Seila, Junior Finance Manager, Johanniter International Assistant និងតំណាងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ<br>អង្គការ គ.ស.ក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia